ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



# របបថែទាំសុខភាពសម្រាប់បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ

សង្ខេបគោលនយោបាយ : លេខ៧ / ខែសីហា ឆ្នាំ២០២៣

ជាមួយនឹងសុខសន្តិភាព ស្ថេរភាពនយោបាយ និងការគិតគូរយ៉ាងមធ្យ៉ត់អំពីសុខុមាលភាពរបស់ប្រជាជនកម្ពុជា ដោយឈរលើគោលការណ៍ “**មិនបោះបង់ពលរដ្ឋណាម្នាក់**”, រាជរដ្ឋាភិបាលកម្ពុជា តាមរយៈសេចក្តីប្រកាសព័ត៌មានលេខ ០២ ប្រកព ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ បានសម្រេចដាក់ឱ្យអនុវត្តរបបថែទាំសុខភាពតាមរយៈមូលនិធិសមធម៌សុខាភិបាល សម្រាប់បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាពិសេសស្រ្តីដែលបម្រើការនៅតាមរង្គសាល, ឌីស្កូតែក, ខារ៉ាអូខេ, បៀរហ្គាឌិន, កន្លែងម៉ាស្សា និងស្ប៉ា។ ការដាក់ចេញនូវអន្តរាគមន៍គាំពារសង្គមបន្ថែមនេះ មានគោលបំណងធានានូវសន្តិសុខប្រាក់ចំណូល, និងកាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំដៅរក្សាលំនឹងជីវិភាព និងទប់ស្កាត់ឱ្យបានជាអតិបរមា កុំឱ្យពលរដ្ឋគោលដៅធ្លាក់ចូលក្នុងភាពក្រីក្រ ដោយសារការធ្លាក់ខ្លួនឈឺ។

## អ្វីទៅជាមូលនិធិសមធម៌សុខាភិបាល?

**មូលនិធិសមធម៌សុខាភិបាល** សំដៅដល់យន្តការហិរញ្ញប្បទានផ្នែកគាំពារសុខភាពសង្គមដើម្បីផ្តល់លទ្ធភាពដល់ក្រុមពលរដ្ឋគោលដៅ ឱ្យទទួលបាន ឬប្រើប្រាស់សេវាថែទាំសុខភាពដោយឥតបង់ថ្លៃ នៅមូលដ្ឋានសុខាភិបាលសាធារណៈ ដោយរាជរដ្ឋាភិបាលជាអ្នកទទួលបន្ទុកបង់ថ្លៃជំនួស។ កន្លងមក មូលនិធិសមធម៌សុខាភិបាល បានផ្តល់ការគាំពារផ្នែកសុខភាពជូនពលរដ្ឋដែលមានបណ្ណសមធម៌ប្រមាណ ៧០ ម៉ឺននាក់ ស្មើនឹង ២,៨ លាននាក់ និងកម្មករនិយោជិតក្រៅប្រព័ន្ធ និងក្រុមគោលដៅជាក់លាក់ (រួមមានមេភូមិ, អនុភូមិ, ជំនួយការភូមិ, ក្រុមប្រឹក្សាឃុំ-សង្កាត់, កីឡាករ-កីឡាការិនី, អ្នកធាក់ស៊ីក្លូ និង បុគ្គលិកនិងអ្នកជំនាញដោះមីន) ប្រមាណ ១០ម៉ឺននាក់។



## យន្តការអនុវត្ត និងការផ្តល់តាវកាលិក (អត្ថប្រយោជន៍)

យន្តការអនុវត្ត និងការផ្តល់តាវកាលិក ក្រោមរបបថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធនេះ ត្រូវបានកំណត់ដោយប្រកាសអន្តរក្រសួងលេខ ៣៥៨. សហវ. ប្រក. អកគ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣។




តាមរយៈប្រកាសអន្តរក្រសួងនេះ រាជរដ្ឋាភិបាលតម្រូវឱ្យនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ក្នុងវិស័យសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ រៀបចំបញ្ជីឈ្មោះបុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក្នុងសហគ្រាស ឬគ្រឹះស្ថានរបស់ខ្លួន ហើយត្រូវបញ្ជូន ទៅរដ្ឋបាលរាជធានី-ខេត្ត ឬក្រុង/ស្រុក/ខណ្ឌ សម្រាប់ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ មុននឹងស្នើទៅបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ដើម្បីចុះបញ្ជី។

ដោយឡែក បុគ្គលបម្រើការងារដែលមិនស្ថិតក្រោមកិច្ចសន្យាការងារក្នុងវិស័យសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក៏មានសិទ្ធិដាក់ពាក្យស្នើសុំបណ្ណមូលនិធិសមធម៌សុខាភិបាលដោយផ្ទាល់ ទៅរដ្ឋបាលរាជធានី-ខេត្ត ឬក្រុង/ស្រុក/ខណ្ឌ សម្រាប់ផ្ទៀងពីភាពត្រឹមត្រូវ មុននឹងស្នើទៅ **ប.ស.ស.** ដើម្បីចុះបញ្ជី។






ក្នុងការទទួលសេវាសុខាភិបាល, បុគ្គលបម្រើការក្នុងវិស័យសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ត្រូវប្រើប្រាស់មូលដ្ឋានសុខាភិបាលសាធារណៈ ដោយអនុវត្តតាមប្រព័ន្ធផ្តល់សេវា ពីថ្នាក់បឋមនៅមូលដ្ឋានសុខាភិបាលថ្នាក់ទាប ទៅមូលដ្ឋានសុខាភិបាលថ្នាក់ខ្ពស់ជាង លើកលែងតែក្នុងករណីសង្គ្រោះបន្ទាន់ប៉ុណ្ណោះ។

## តួនាទី និងភារកិច្ច

**និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ក្នុងវិស័យសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ** ត្រូវរៀបចំបញ្ជីឈ្មោះបុគ្គលបម្រើការក្នុងវិស័យសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក្នុងសហគ្រាស ឬគ្រឹះស្ថានរបស់ខ្លួន ហើយត្រូវបញ្ជូនទៅរដ្ឋបាលរាជធានី-ខេត្ត ឬក្រុង/ស្រុក/ខណ្ឌ សម្រាប់ផ្ទៀងពីភាពត្រឹមត្រូវ ឬបុគ្គលបម្រើការក្នុងវិស័យសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ត្រូវទៅដាក់ពាក្យស្នើសុំនៅរដ្ឋបាលរាជធានី-ខេត្ត ឬក្រុង/ស្រុក/ខណ្ឌ មុននឹងស្នើទៅបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ដើម្បីចុះបញ្ជី។

**រដ្ឋបាលរាជធានី-ខេត្ត ឬក្រុង/ស្រុក/ខណ្ឌ** មានតួនាទីពិនិត្យ និងផ្ទៀងពីភាពត្រឹមត្រូវនៃបញ្ជីឈ្មោះរបស់បុគ្គលបម្រើការក្នុងវិស័យសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ប.ស.ស. ទទួលបន្ទុកចុះបញ្ជី និងចេញបណ្ណមូលនិធិសមធម៌សុខាភិបាល (បណ្ណ ម.ស.ស.) ដែលមានសុពលភាពរយៈពេលមួយឆ្នាំ ជូនបុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។

**ក្រុមប្រឹក្សាជាតិគាំពារសង្គម** មានតួនាទីដឹកនាំការតាមដាន ត្រួតពិនិត្យប្រសិទ្ធភាព និងការវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តរបបមូលនិធិសមធម៌សុខាភិបាល។




( បណ្ណ ប.ស.ស. )




( បណ្ណ ម.ស.ស. )

ករណីបុគ្គលបម្រើការងារក្នុងសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាពិសេសស្ត្រីដែលមានការលំបាកផ្នែកជីវភាពឆ្លើយតបនឹងលក្ខខណ្ឌគ្រប់គ្រាន់អាចទទួលបានបណ្ណសមធម៌ (បណ្ណក្រីក្រ) ពីក្រសួងផែនការ តែមិនទាន់បានទទួល ដោយសារកត្តាសត្យានុម័តណាមួយ, រាជរដ្ឋាភិបាលដែលមានក្រុមប្រឹក្សាជាតិគាំពារសង្គមជាសេនាធិការ នឹងសម្របសម្រួលរៀបចំយុទ្ធនាការផ្តល់បណ្ណសមធម៌ (បណ្ណក្រីក្រ) ជូនជាបន្តបន្ទាប់ ស្របពេលជាមួយនឹងយុទ្ធនាការចុះបញ្ជី និងផ្តល់បណ្ណ ម.ស.ស. ជូនក្រុមគោលដៅដែលជាបុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយ ប.ស.ស.។



(បណ្ណសមធម៌)

រាល់ចំណាយលើការផ្តល់សេវាថែទាំសុខភាពសម្រាប់បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលត្រូវហិរញ្ញប្បទានដោយថវិកាជាតិ៕